**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

ក្រុមប្រឹក្សា
កំណែទម្រង់ច្បាប់ និងប្រព័ន្ធយុត្តិធម៌
អគ្គលេខាធិការដ្ឋាន
លេខៈ០២១/០៩ រប.កកចយ

## របាយការណ៍ស្តីពីសកម្មភាពការងារប្រចាំខែ កញ្ញា ឆ្នាំ ២០០៩ របស់ក្រុមប្រឹក្សាកំណែទម្រង់ច្បាប់ និងប្រព័ន្ធយុត្តធម៌និងទិសដៅសម្រាប់អនុវត្តបន្ត

ក្នុងខែ កញ្ញា ឆ្នាំ២០០៩ អគ្គលេខាធិការដ្ឋាននៃក្រុមប្រឹក្សាកំណែទម្រង់ច្បាប់ និងប្រព័ន្ធយុត្តិធម៌បាន ដំណើរការងាររបស់ខ្លួនស្របតាមបេសកកម្មដែលបានកំណត់ ក្នុងស្មារតីទទួលខុសត្រូវខ្ពស់ ហើយសម្រេចបាននូវលទ្ធផលជាក់ស្តែងដូចខាងក្រោម ៖

### ១-ការងារកំណែទម្រង់ច្បាប់ និងប្រព័ន្ធយុត្តធម៌

### ក. ការងាររដ្ឋបាល

- ផ្ញើលិខិតលេខ ០៨៨/០៩ លស.កកចយ ចុះថ្ងៃទី៣១ ខែសីហា ឆ្នាំ២០០៩ ស្តីពីការរៀបចំសិក្ខាសាលាស្តីពីកម្មវិធីវេទិការផ្លាស់ប្តូរយោបល់ជាមួយភ្នាក់ងារអនុវត្ត និងសង្គមស៊ីវិលលើបញ្ហាកំណែទម្រង់ច្បាប់ និងតុលាការនៅតាមបណ្តាខេត្តចំនួនបួនៈគឺ ខេត្តកំពង់ចាម កំពងធំ ព្រៃវែង និងខេត្តបន្ទាយមានជ័យ។
- ផ្ញើលិខិតលេខ ០៦៩/០៩ លស.កកចយ ចុះថ្ងៃទី០១ ខែកញ្ញា ឆ្នាំ២០០៩ ជូន លោក អ៊ីវ ហ៊ាង ប្រធាននាយកដ្ឋានរដ្ឋបាល និងហិរញ្ញវត្ថុនៃឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រម ស្តីពីសំណើសុំព្រះរាជក្រិត្យ ស្តីពីការចូលនិវត្តន៍ ការតែងតាំង ការចូលកាន់តំណែងថ្មីរបស់ចៅក្រមព្រះរាជអាជ្ញា ទូទាំងប្រទេស។
- ផ្ញើលិខិតលេខ ០៧០/០៩ លស.កកចយ ចុះថ្ងៃទី ០១ ខែកញ្ញា ឆ្នាំ២០០៩ ជូន ឯកឧត្តម ង៉ោ ហុងលី អគ្គលេខាធិការនៃក្រុមប្រឹក្សាកំណែទម្រង់រដ្ឋបាល ស្តីពីកំណែទម្រង់ច្បាប់ និងប្រព័ន្ធយុត្តិធម៌សម្រាប់ផែនការ សកម្មភាពអភិបាលកិច្ចទី៣ ។
-ផ្ញើលិខិតលេខ ០៧១/០៩ ចុះថ្ងៃទី០៣ ខែកញ្ញា ឆ្នាំ២០០៩ សំណើអញ្ជើញសមាជិកក្រុមប្រឹក្សា កំណែទម្រង់ច្បាប់ និងប្រព័ន្ធយុត្តិធម៌ ប្រធានសាលាដំបូង នៃតុលាការគំរូទាំងបួន រាជធានី-ខេត្ត និងស្ថាប័នពាក់ព័ន្ធមួយចំនួនដើម្បីចូលរួមប្រជុំក្រុមប្រឹក្សាកំណែទម្រង់ច្បាប់ និងប្រព័ន្ធយុត្តិធម៌ នៅថ្ងៃទី១៥ ខែកញ្ញា ឆ្នាំ២០០៩ វេលាម៉ោង ០៩ៈ០០ នាទីព្រឹក ។
- ផ្ញើលិខិតលេខ ០៧២/០៩ លស.កកចយ ចុះថ្ងៃទី០៧ ខែកញ្ញ ឆ្នាំ២០០៩ សំណើសុំបញ្ជូនឈ្មោះមន្ត្រីរាជការនៃអគ្គលេខាធិការដ្ឋាននៃក្រុមប្រឹក្សាកំណែទម្រង់ច្បាប់ និងប្រព័ន្ធយុត្តិធម៌ដែលត្រូវស្នើសុំគ្រឿងឥស្សរិយៈ យសសម្រាប់ឆ្នាំ២០០៩ ។

- ផ្ញើលិខិតលេខ ០៧៣/០៩ លស.កកចយ ចុះថ្ងៃទី០៧ ខែកញ្ញ ឆ្នាំ២០០៩ សំណើសុំបញ្ជូនឈ្មោះមន្ត្រីរាជការនៃអគ្គលេខាធិការដ្ឋាននៃក្រុមប្រឹក្សាកំណែទម្រង់ច្បាប់ និងប្រព័ន្ធយុត្តិធម៌ដែលត្រូវតម្លើងបៀវត្សប្រចាំ ឆ្នាំ២០០៩ ។

- ផ្ញើលិខិតលេខ ០៧៤/០៩ លស.កកចយ ចុះថ្ងៃទី០៧ ខែកញ្ញ ឆ្នាំ២០០៩ សំណើសុំបញ្ជូនឈ្មោះមន្ត្រី ជាប់កិច្ចសន្យានៃអគ្គលេខាធិការដ្ឋាននៃក្រុមប្រឹក្សាកំណែទម្រង់ច្បាប់ និងប្រព័ន្ធយុត្តិធម៌សម្រាប់ឆ្នាំ២០០៩ ។

- ផ្ញើលិខិតលេខ ០៧៥/០៩ លស.កកចយ ចុះថ្ងៃទី០៨ ខែកញ្ញា ឆ្នាំ២០០៩ សំណើអញ្ជើញចូលរួមប្រជុំ ក្រុមប្រឹក្សាកំណែទម្រង់ច្បាប់ និងប្រព័ន្ធយុត្តិធម៌នៅថ្ងៃទី១៦ ខែកញ្ញា ឆ្នាំ២០០៩ វេលាម៉ោង ៩ៈ០០ នាទីព្រឹក។

-ផ្ញើលិខិត ០៧៦/០៩ លស.កកចយ ចុះថ្ងៃទី១០ ខែកញ្ញា ឆ្នាំ២០០៩ សំណើសុំ លិខិតបេសកកម្ម និងប័ណ្ណដើរផ្លូវសម្រាប់ថ្នាក់ដឹកនាំ និងមន្ត្រីនៃអគ្គលេខាធិការដ្ឋាន នៃក្រុមប្រឹក្សាកំណែទម្រង់ច្បាប់ និងប្រព័ន្ធយុត្តិធម៌ ចុះទៅធ្វើទំនាក់ទំនងជាមួយសាលាខេត្ត ដើម្បីចុះទៅធ្វើសិក្ខាសាលា ស្តីពីកម្មវិធីវេទិការផ្លាស់ប្តូរយោបល់ រវាងភ្នាក់ងារអនុវត្ត និងសង្គមស៊ីវិល លើបញ្ហាកំណែទម្រង់ច្បាប់ និងតុលាការនៅខេត្តកំពង់ធំ។

-ផ្ញើលិខិត ០៧៧/០៩ លស.កកចយ ចុះថ្ងៃទី១០ ខែកញ្ញា ឆ្នាំ២០០៩ សំណើសុំ លិខិតបេសកកម្ម និង ប័ណ្ណដើរផ្លូវសម្រាប់ថ្នាក់ដឹកនាំ និងមន្ត្រីនៃអគ្គលេខាធិការដ្ឋាន នៃក្រុមប្រឹក្សាកំណែទម្រង់ច្បាប់ និងប្រព័ន្ធយុត្តិធម៌ ដើម្បីចុះទៅរៀបចំសិក្ខាសាលា ស្តីពីកម្មវិធីវេទិការផ្លាស់ប្តូរយោបល់ រវាងភ្នាក់ងារអនុវត្ត និងសង្គមស៊ីវិលលើបញ្ហាកំណែទម្រង់ច្បាប់ និងតុលាការ ដើម្បីពិចារណារកវិធីសាស្ត្រដែលល្អប្រសើរ សម្រាប់អនុវត្តយុទ្ធសាស្ត្រកំណែ ទម្រង់ច្បាប់ និងតុលាការនៅខេត្តបន្ទាយមានជ័យ ។

-ផ្ញើលិខិតលេខ ០៧៨/០៩ លស.កកចយ ចុះថ្ងៃទី១១ ខែកញ្ញ ឆ្នាំ២០០៩ ស្តីពីសំណើសុំចាត់មន្ត្រី ០៤រូប ដើម្បីទៅចូលរួមកម្មវិធីបណ្តុះបណ្តាលសម្រាប់អ្នកដឹកនាំវ័យក្មេង នៅទីក្រុងតូក្យូប្រទេសជប៉ុន ។

-ផ្ញើលិខិតលេខ ០៧៩/០៩ លស.កកចយ ចុះថ្ងៃទី១១ ខែកញ្ញា ឆ្នាំ ២០០៩ សំណើសុំលិខិតបេសកកម្ម និងប័ណ្ណដើរផ្លូវសម្រាប់ថ្នាក់ដឹកនាំ និងមន្ត្រីនៃអគ្គលេខាធិការដ្ឋាន នៃក្រុមប្រឹក្សាកំណែទម្រង់ច្បាប់ និងប្រព័ន្ធ យុត្តិធម៌ចុះទៅធ្វើទំនាក់ទំនងជាមួយសាលាខេត្ត ដើម្បីចុះទៅចូលរួមសិក្ខាសាលា ស្តីពីកម្មវិធីវេទិការផ្លាស់ប្តូរយោបល់ រវាងភ្នាក់ងារអនុវត្ត និងសង្គម-ស៊ីវិលលើបញ្ហាកំណែទម្រង់ច្បាប់ និងតុលាការនៅខេត្ត កំពង់ចាម។

-ផ្ញើលិខិតលេខ ០៨០/០៩ លស.កកចយ ចុះថ្ងៃទី១១ ខែកញ្ញា ឆ្នាំ២០០៩ សំណើសុំលិខិតបេសកកម្ម និងប័ណ្ណដើរផ្លូវសម្រាប់ថ្នាក់ដឹកនាំ និងមន្ត្រីនៃអគ្គលេខាធិការដ្ឋាន នៃក្រុមប្រឹក្សាកំណែទម្រង់ច្បាប់ និងប្រព័ន្ធយុត្តិធម៌ ចុះទៅធ្វើទំនាកទំនងជាមួយសាលាខេត្ត ដើម្បីចុះទៅចូលរួមសិក្ខាសាលា ស្តីពីកម្មវិធីវេទិការផ្លាស់ប្តូរ យោបល់រវាងភ្នាក់ងារអនុវត្ត និងសង្គមស៊ីវិលលើបញ្ហាកំណែទម្រង់ច្បាប់ និងតុលាការនៅខេត្ត ព្រៃវែង។

- ផ្ញើលិខិតលេខ ០៨១/០៩ លស.កកចយ ចុះថ្ងៃទី១១ ខែកញ្ញា ឆ្នាំ២០០៩ សំណើសុំលិខិតបេសកកម្ម និងប័ណ្ណដើរផ្លូវសម្រាប់ថ្នាក់ដឹកនាំ និងមន្ត្រីនៃអគ្គលេខាធិការដ្ឋាន នៃក្រុមប្រឹក្សាកំណែទម្រង់ច្បាប់ និងប្រព័ន្ធយុត្តិធម៌ចុះទៅធ្វើទំនាក់ទំនងជាមួយសាលាខេត្ត ដើម្បីចុះទៅចូលរួម

សិក្ខាសាលាស្តីពីកម្មវិធីវេទិការផ្លាស់ប្តូរ យោបល់រវាងភ្នាក់ងារអនុវត្ត និងសង្គមស៊ីវិលលើបញ្ហាកំណែទម្រង់ច្បាប់ និងតុលាការនៅខេត្តកំពង់ធំ នៅថ្ងៃទី ០៦ ខែតុលា ឆ្នាំ២០០៩។

- ផ្ញើលិខិតលេខ ០៨២/០៩ លស.កកចយ ចុះថ្ងៃទី១៤ ខែកញ្ញា ឆ្នាំ២០០៩ សំណើលើកកិច្ចប្រជុំក្រុមប្រឹក្សាកំណែទម្រង់ច្បាប់ និងប្រព័ន្ធយុត្តិធម៌ ដែលគ្រោងធ្វើនៅថ្ងៃពុធទី១៦ ខែកញ្ញា ឆ្នាំ២០០៩ ។

-ផ្ញើលិខិតលេខ ០៨៣/០៩ លស.កកចយ ចុះថ្ងៃទី២៣ ខែកញ្ញា ឆ្នាំ២០០៩ សំណើសុំផ្ញើលិខិតឆ្លងដែន ផ្លូវការ និងកំណត់ទូត ជូនមន្ត្រីនៃអគ្គលេខាធិការដ្ឋាននៃក្រុមប្រឹក្សាកំណែទម្រង់ច្បាប់ និងប្រព័ន្ធយុត្តិធម៌។

-ផ្ញើលិខិតលេខ ០៨៤/០៩ លអ.កកចយ ចុះថ្ងៃទី៣០ ខែកញ្ញា ឆ្នាំ២០០៩ ស្តីពីការអញ្ជើញចូលរួមប្រជុំក្រុមការងារបច្ចេកទេសចម្រុះកំណែទម្រង់ច្បាប់ និងតុលាការនៅថ្ងៃទី០៥ ខែតុលា ឆ្នាំ២០០៩ វេលាម៉ោង ១៤:៣០ នាទី នៅទីស្តីការគណៈរដ្ឋមន្ត្រី។

-បានទទួលលិខិតលេខ ១១៩៤/០៩ កអក/គ.ជ.នា ចុះថ្ងៃទី ២៤ ខែសីហា ឆ្នាំ២០០៩ ពីក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា ស្តីពីការអញ្ជើញចូលរួមក្នុងកិច្ចប្រជុំលើកទី ១៥ របស់ក្រុមការងារបច្ចេកទេសចម្រុះ ស្តីពីភាពជាដៃគូ និងសុខដុមនីយកម្ម ។

-បានទទួលលិខិតលេខ ១៩២ រប.៩២១-០៩ ចុះថ្ងៃទី២៨ ខែសីហា ឆ្នាំ២០០៩ ពីសាលាដំបូងរាជធានីភ្នំពេញ នូវដីការសម្រេច ស្តីពីការកែសម្រួលសមាសភាពក្រុមការងារតុលាការគំរូរបស់សាលាដំបូងរាជធានីភ្នំពេញ ។

- បានទទួលលិខិតពី កម្មវិធីអភិវឌ្ឍន៍របស់អង្គការ (UNDP) ចុះថ្ងៃទី៣ ខែកញ្ញ ឆ្នាំ២០០៩ ស្តីពី Review and Publication of Handbooks and Manual, Minutes of Board Meeting on August 25, 2009 in Imperial Hotel.

-បានទទួលលិខិតលេខ ៣៨៨ លអជ.រប ចុះថ្ងៃទី០៤ ខែកញ្ញា ឆ្នាំ២០០៩ អញ្ជើញចូលរួមក្នុងអង្គប្រជុំអន្តរក្រសួង ដើម្បីពិភាក្សាលើសេចក្តីព្រាងអនុក្រឹត្យ ស្តីពីការចាត់ថ្នាក់ និងដាក់ស្លាកសញ្ញា សារធាតុគីមី។

-បានទទួលដីការអមលេខ ៥៩៧/០៩/របវត/អគជ ចុះថ្ងៃទី០៤ ខែកញ្ញ ឆ្នាំ២០០៩ ស្តីពីលិខិតអញ្ជើញ ចៅក្រម និងព្រះរាជអាជ្ញា ចូលរួមវគ្គបណ្តុះបណ្តាលបន្តស្តីពី “សេចក្តីព្រាងក្រមព្រហ្មទណ្ឌ-ក្រមនីតិវិធីព្រហ្មទណ្ឌ និងច្បាប់ស្តីពីការបង្ក្រាបអំពើជួញដូរមនុស្ស និងអំពើធ្វើអាជីវកម្មផ្លូវភេទ” ដែលនឹងប្រព្រឹត្តទៅនៅថ្ងៃទី២៨-៣០ ខែកញ្ញា និង ០១-០២ ខែតុលា ឆ្នាំ២០០៩ នៅរាជបណ្ឌិតសភាវិជ្ជាជីវៈតុលាការ។

-បានទទួលលិខិតលេខ ២៣៦ រប.០៩ ចុះថ្ងៃទី០៧ ខែកញ្ញា ឆ្នាំ២០០៩ ពីឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រម នូវកម្រងសាលក្រមរបស់សាលដំបូងរាជធានី-ខេត្ត លេខ៦.៧.៨ និងលេខ៩ មាន ២០ក្បាល។

-បានទទួលលិខិតពី អង្គការសហប្រជាជាតិប្រចាំប្រទេសកម្ពុជា ចុះថ្ងៃទី០៧ ខែកញ្ញា ឆ្នាំ២០០៩ ស្តីពី: Invitation of participation in the (UNDAF) Working Group Govermence.

-បានទទួលលិខិតលេខ ៣៨៩ លអជ.រប ចុះថ្ងៃទី០៨ ខែកញ្ញា ឆ្នាំ២០០៩ ពីទីស្តីការគណៈរដ្ឋមន្ត្រី អញ្ជើញចូលរួមជាមួយ ឯកឧត្តម សុខ អាន ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី ក្នុងការអនុញ្ញាតឱ្យលោក David Cowen ប្រធានបេសកកម្ម IMF ចូលជួប

ពិភាក្សាការងារមួយចំនួន ដែលនឹងប្រព្រឹត្តទៅ នៅថ្ងៃទី១៧ ខែកញ្ញា ឆ្នាំ២០០៩ វេលាម៉ោង ១១ៈ០០។

-បានទទួលលិខិតលេខ ១២៦២ សជណ.កបច ចុះថ្ងៃទី១១ ខែកញ្ញា ឆ្នាំ២០០៩ ពីទីស្តីការគណៈរដ្ឋមន្ត្រី ស្តីពីៈ អំពីការពង្រឹងតួនាទី និងសកម្មភាពក្រុមប្រឹក្សាវិន័យ នៃឧត្តម នៃអង្គចៅក្រម។

-បានទទួលលិខិតលេខ ៣៩១ លអជ.រប ចូលរួមប្រជុំក្នុងអន្តរក្រសួងដើម្បីៈ ពិភាក្សាលើកម្មវិធីកសាង លិខិតបទដ្ឋានគតិយុត្តរបស់ក្រសួង-ស្ថាប័ន ដើម្បីរៀបចំជាកម្មវិធីកសាងលិខិតបទដ្ឋានគតិយុត្ត របស់រាជរដ្ឋាភិបាល សម្រាប់នីតិកាលទី៤ នៃរដ្ឋសភា ។

-បានទទួលលិខិតលេខ JC២១-៥៣៦ ចុះថ្ងៃទី១១ ខែកញ្ញា ឆ្នាំ២០០៩ ពីទីភ្នាក់ងារសហប្រតិបត្តិការអន្តរជាតិនៃប្រទេសជប៉ុន (JICA) ស្តីពីកម្មវិធីបណ្តុះបណ្តាលអ្នកដឹកនាំវ័យក្មេង នៅប្រទេសជប៉ុនសម្រាប់ឆ្នាំ២០០៩ ពីថ្ងៃទី១៥ ខែវិច្ឆិកា ដល់ថ្ងៃទី២ ខែធ្នូ ឆ្នាំ២០០៩។

-បានទទួលលិខិតលេខ ១២៧៤ សជណ.រប ចុះថ្ងៃទី១៤ ខែកញ្ញា ឆ្នាំ២០០៩ ពីទីស្តីការគណៈរដ្ឋមន្ត្រី ស្តីពីការលើកពេលវេលា ដែលត្រូវចូលរួមក្នុងពិធីចុះហត្ថលេខាលើគម្រោងស្តារឡើងវិញនូវវិស័យសិប្បកម្មតម្បាញសូត្រដែលនឹងប្រព្រឹត្តទៅនៅថ្ងៃទី១៧ ខែកញ្ញា ឆ្នាំ២០០៩ វេលាម៉ោង ១៦ៈ០០ នាទី ត្រូវបានលើកពេលវេលា មកម៉ោង ០៩ៈ៣០ នាទីវិញ ឯថ្ងៃ ខែ ឆ្នាំ រក្សាទុកនៅដដែល។

- បានទទួលលិខិតលេខ ៣៩៦ លអជ.រប ចុះថ្ងៃទី១១ ខែកញ្ញា ឆ្នាំ២០០៩ អញ្ជើញចូលរួមជាកិត្តិយស ក្នុងពិធីចុះហត្ថលេខា លើគម្រោងស្តារឡើងវិញនូវវិស័យសិប្បកម្មតម្បាញសូត្រ ជាមួយអង្គការ FAO ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់របស់ ឯកឧត្តម សុខ អាន ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី ដែលនឹង ប្រព្រឹត្តទៅនៅថ្ងៃទី១៧ ខែកញ្ញា ឆ្នាំ២០០៩ វេលាម៉ោង ១៦ៈ០០ នាទី ។

-បានទទួលលិខិត FAO/CMB/1/09/523 ចុះថ្ងៃទី១៥ ខែកញ្ញា ឆ្នាំ២០០៩ ពីអង្គការស្បៀង និងកសិកម្ម នៃសហប្រជាជាតិស្តីពី ៖ FRepuest for Appoinment-Missionary of Dr.Larry Copeland, FAO Expert in Food Control Management

-បានទទួលលិខិតលេខ ៧២៥ /គ.ម/០៩ ចុះថ្ងៃទី១៥ ខែកញ្ញា ឆ្នាំ២០០៩ ពីគណៈមេធាវីនៃព្រះរាជាណាចក្រកម្ពុជា អញ្ជើញចូលរួមមហាសន្និបាតប្រចាំឆ្នាំ លើកទី១៤ របស់គណៈមេធាវី និងចូលរួមបោះឆ្នោតជ្រើសតាំង សមាជិកក្រុមប្រឹក្សាគណៈមេធាវី អាណត្តិទី ៦ (២០០៩-២០១០)។

-បានទទួលលិខិតលេខ ៤០៣ លអជ.រប ចុះថ្ងៃទី២២ ខែកញ្ញា ឆ្នាំ២០០៩ អញ្ជើញចូលរួមជាកិត្តិយស ក្នុងពិធីចុះហត្ថលេខាលើវិសោធនកម្មលេខ១ នៃកិច្ចព្រមព្រៀងផ្តល់ជំនួយរវាងរដ្ឋាភិបាលអាមេរិក និងរាជរដ្ឋាភិបាលកម្ពុជា សម្រាប់កម្មវិធី “កំណើនសេដ្ឋកិច្ច”របស់ USAID ជាមួយលោក Flynn Fuller នាយកបេសកកម្ម USAID នៅកម្ពុជា ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់របស់ ឯកឧត្តម សុខ អាន ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីទទួល បន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី ដែលនឹងប្រព្រឹត្តទៅនៅថ្ងៃទី២៣ ខែកញ្ញា ឆ្នាំ២០០៩ វេលាម៉ោង ៩ៈ០០នាទី នៅ ទីស្តីការគណៈរដ្ឋមន្ត្រី។

-បានទទួលលិខិតលេខ ១០១៦/០៩០៩/អ.ពស/ពក ចុះថ្ងៃទី២២ ខែកញ្ញា ឆ្នាំ២០០៩ ពីអគ្គលេខាធិការដ្ឋានព្រឹទ្ធសភា ស្តីពីការអញ្ជើញ ឯកឧត្តមអគ្គលេខាធិការ នៃក្រុមប្រឹក្សាកំណែទម្រង់ច្បាប់ និងប្រព័ន្ធយុត្តិធម៌ ចូលរួមក្នុងអង្គសន្និសីទ “ ការរំលឹកខួបលើកទី ៦០ នៃច្បាប់រដ្ឋធម្មនុញ្ញអាល្លឺម៉ង់ និងគម្រប់ខួប ២០ ឆ្នាំនៃការរួបរួមគ្នាឡើងវិញរបស់សាធារណរដ្ឋសហព័ន្ធ

អាល្លីម៉ង់ ” ដែលនឹងប្រព្រឹត្តទៅនៅថ្ងៃទី០៨ ខែតុលា ឆ្នាំ២០០៩ វេលាម៉ោង ១៤ៈ០០ រសៀល នៅសណ្ឋាគារឡឺរយ៉ាល់ ។

-បានទទួលអនុក្រឹត្យ លេខ ១៦០.អនក្រ.បក ចុះថ្ងៃទី២៣ ខែកញ្ញា ឆ្នាំ២០០៩ ស្តីពីការបង្កើនប្រសិទ្ធភាពការងាររបស់ឧត្តមក្រុមប្រឹក្សាវិន័យនៃឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រម។

-បានទទួលលិខិតលេខ ៤០៤ លអជ.រប ចុះថ្ងៃទី២២ ខែកញ្ញា ឆ្នាំ២០០៩ អញ្ជើញចូលរួមជាកិត្តិយស ក្នុងពិធីសម្ពោធដាក់ឱ្យប្រើប្រាស់ បណ្ណាល័យអេឡិចត្រូនិច ឧបត្ថម្ភដោយសមាគមចិន-អាស៊ាន តាមរយៈស្ថានទូត នៃសាធារណៈរដ្ឋប្រជាមានិតចិន ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់របស់ឯកឧត្តម សុខ អាន ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី និងលោកជំទាវ ដែលនឹងប្រព្រឹត្តទៅនៅថ្ងៃទី៣០ ខែកញ្ញា ឆ្នាំ២០០៩ វេលាម៉ោង ០៨ៈ៣០ នាទី នៅរាជបណ្ឌិតសភាកម្ពុជា ។

-បានទទួលលិខិតពីអង្គការខុនរ៉ាត់អាដេណូអឺ (Konrad Adenauer Stiftung) អញ្ជើញចូលរួមប្រជុំក្នុងសន្និសីទអន្តរជាតិស្តីពី លក្ខន្តិកៈទីក្រុងរ៉ូម និងប្រទេសកម្ពុជា ការអនុវត្តន៍បទដ្ឋានអន្តរជាតិ នៅថ្ងៃទី២២ ខែកញ្ញា ឆ្នាំ២០០៩ នៅសណ្ឋាគារ Sunway ក្រុងភ្នំពេញ។

-បានទទួលលិខិតលេខ ៤០៩ លអជ.រប ចុះថ្ងៃទី២៣ ខែកញ្ញា ឆ្នាំ២០០៩ អញ្ជើញចូលរួមក្នុងអង្គប្រជុំអន្តរក្រសួង ដើម្បីពិភាក្សាលើសេចក្តីព្រាងអនុក្រឹត្យ ស្តីពីនីតិវិធីនៃការវិនិយោគ ការដេញថ្លៃជាសាធារណៈ ឬការជួលតាមការព្រមព្រៀង និងការបង់ថ្លៃឈ្នួលនេសាទ ដែលនឹងប្រព្រឹត្តទៅនៅថ្ងៃទីព្រហស្បត៍ទី០១ ខែតុលា ឆ្នាំ២០០៩ វេលាម៉ោង ០៨ៈ៣០ នាទី។

-បានទទួលលិខិតលេខ ៣៩២ កអជ.រប ចុះថ្ងៃទី០៩ ខែកញ្ញា លិខិតលេខ ៤០១ ចុះថ្ងៃទី១៦ ខែកញ្ញា និង៤១០ លអជ.រប ចុះថ្ងៃទី២៣ ខែកញ្ញា ឆ្នាំ២០០៩ អញ្ជើញចូលរួមក្នុងអង្គប្រជុំអន្តរក្រសួងដើម្បីពិភាក្សា លើសេចក្តីព្រាងអនុក្រឹត្យ ស្តីពីលក្ខ័ណ្ឌ និងបែបបទនៃការធ្វើជំរើន ការជ្រើសរើស ការអញ្ជើញ ការពន្យាពេល នៃយុវជនកំពុងជាប់ការសិក្សា ប្រជាពលរដ្ឋ ដែលស្ថិតក្នុងករណីពិសេស និងសមត្ថកិច្ច ក្នុងការអនុវត្តន៍ច្បាប់ កាតព្វកិច្ចយោធា ដែលនឹងប្រព្រឹត្តទៅនៅថ្ងៃពុធទី៣០ ខែកញ្ញា ឆ្នាំ២០០៩ វេលាម៉ោង ០៨ៈ៣០ នាទី។

-បានទទួលលិខិតលេខ ៧៥១/គ.ម/០៩ ចុះថ្ងៃទី២៥ ខែកញ្ញា ឆ្នាំ២០០៩ ពីគណៈមេធាវី នៃព្រះរាជាណាចក្រកម្ពុជា អញ្ជើញចូលរួមសិក្ខាសាលារបស់គណៈមេធាវី ដែលនឹងប្រព្រឹត្តទៅនៅថ្ងៃទី០៧ ខែតុលា ឆ្នាំ២០០៩ ចាប់ពីម៉ោង ០៧ៈ៣០ នាទី ដល់ម៉ោង ១៧ៈ៣០ នាទី នៅសណ្ឋាគាភ្នំពេញ។

-បានទទួលលិខិត ពីគម្រោងជំនួយផ្នែកព្រហ្មទណ្ឌនិងយុត្តិធម៌នៅកម្ពុជា CCJAPIII អញ្ជើញចូលរួម ប្រជុំស្តីពីផែនការការងារនៅថ្ងៃទី៣០ ខែកញ្ញា ឆ្នាំ២០០៩ នៅសណ្ឋាគារអ៊ឹមជីរៀល ភ្នំពេញ វេលាម៉ោង ៩ៈ០០នាទី។

## ខ.ការងារកំណែទម្រង់

-ត្រៀមរៀបចំកិច្ចប្រជុំក្រុមការងារបច្ចេកទេសចម្រុះ សម្រាប់កំណែទម្រង់ច្បាប់ និងតុលាការជាមួយស្ថាប័ន ពាក់ព័ន្ធ និងដៃគូអភិវឌ្ឍន៍នៅថ្ងៃទី៥ ខែតុលា ឆ្នាំ២០០៩ វេលាម៉ោង ១៤ៈ៣០នាទី នៅទីស្តីការគណៈរដ្ឋមន្ត្រី ។

- អគ្គលេខាធិការដ្ឋាននៃក្រុមប្រឹក្សាកំណែទម្រង់ច្បាប់ និងប្រព័ន្ធយុត្តិ បានចុះទៅរៀបចំកម្មវិធីសិក្ខាសាលារយៈពេល ពីរថ្ងៃ ស្តីពីកម្មវិធីវេទិកាផ្លាស់ប្តូរយោបល់ រវាងភ្នាក់ងារអនុវត្ត និងសង្គមស៊ីវិលលើបញ្ហាកំណែទម្រង់ច្បាប់ និងតុលាការ ដើម្បីពិចារណារកវិធីសាស្ត្រ ដែលល្អប្រសើរសម្រាប់អនុវត្តយុទ្ធសាស្ត្រកំណែទម្រង់ច្បាប់ និងតុលាការ ។

-ក្រុមគម្រោងនីមួយៗរបស់អគ្គលេខាធិការដ្ឋាននៃក្រុមប្រឹក្សាកំណែទម្រង់ច្បាប់ និងប្រព័ន្ធយុត្តិធម៌បានរៀបចំ និងធ្វើផែនការការងារសម្រាប់ឆ្នាំ២០០៩។

- បានរៀបចំប្រមូលពត៌មាន និងរៀបចំបោះពុម្ពផ្សាយនូវព្រឹត្តិប័ត្រលេខ០៣ ឆ្នាំទី២ នៃ អគ្គលេខាធិការ ដ្ឋានក្រុមប្រឹក្សាកំណែទម្រង់ច្បាប់ និងប្រព័ន្ធយុត្តិធម៌ ។

## គ. ផ្សេងៗ

- ចូលរួមក្នុងកិច្ចប្រជុំអន្តរក្រសួងផ្សេងៗ

-បានចូលរួមសិក្ខាសាលាស្តីពីការពង្រឹងប្រសិទ្ធភាពនៃភាពជាដៃគូនាថ្ងៃទី០៩-១០ ខែកញ្ញា ឆ្នាំ២០០៩ នៅសណ្ឋាគារ Angkor Century ខេត្តសៀមរាបដែលរៀបដោយ គណៈកម្មាធិការនីតិសម្បទា និងអភិវឌ្ឍន៍កម្ពុជា នៃក្រុមប្រឹក្សាអភិវឌ្ឍន៍(គ.ជ.នា/ក.អ.ក)។ សិក្ខាសាលានេះបានពិភាក្សាលើរបៀបវរៈមាន:

១-ពិនិត្យអំពីតម្លៃនិងអត្ថប្រយោជន៍នៃអភិក្រមស្តីពីភាពជាដៃគូ

២-ស្វែងយល់វិធីសាស្ត្រផ្សេងៗសម្រាប់ជំរុញភាពជាដៃគូ

៣-បណ្តាគោលការណ៍សម្រាប់ភាពជាដៃគូប្រកបដោយប្រសិទ្ធភាព

៤-កំណត់គោលដៅនិងការអនុវត្តន៍ សម្រាប់ពង្រឹងប្រសិទ្ធភាពជាដៃគូ។

## ២-សន្និដ្ឋាន

-ក្នុងខែ កញ្ញា ឆ្នាំ២០០៩ អគ្គលេខាធិការដ្ឋាននៃក្រុមប្រឹក្សាកំណែទម្រង់ច្បាប់ និងប្រព័ន្ធយុត្តិធម៌ ក៏បានបញ្ចប់នូវការរៀបចំផែនការយុទ្ធសាស្ត្ររបស់ខ្លួន ព្រមទាំងបានរៀបចំធ្វើការផ្សព្វផ្សាយ និងបានចុះទៅរៀបចំសិក្ខាសាលាស្តីពីកម្មវិធី វេទិការផ្លាស់ប្តូរយោបល់រវាងភ្នាក់ងារអនុវត្ត និងសង្គមស៊ីវិលលើបញ្ហាកំណែទម្រង់ច្បាប់ និង តុលាការ ដើម្បីពិចារណារកវិធីសាស្ត្រដែលល្អប្រសើរសម្រាប់អនុវត្តយុទ្ធសាស្ត្រ នៅខេត្តបន្ទាយមានជ័យកាលពី ថ្ងៃទី២២-២៣ ខែកញ្ញា ឆ្នាំ២០០៩ និងបន្តធ្វើសិក្ខាសាលានៅខេត្តបីបន្តទៀតនៅក្នុងតុលា។

## ៣-ទិសដៅអនុវត្តក្នុងខែបន្ត

- បន្តអនុវត្តគម្រោងតុលាការគំរូ

- បន្តអនុវត្តគម្រោងប្រព័ន្ធសូចនាករ និងការតាមដានកំណែទម្រង់ច្បាប់ និងតុលាការ

- បន្តអនុវត្តគម្រោងប្រព័ន្ធទិន្នន័យស្តីពីការលើកកំពស់សិទ្ធិនៅតាមមូលដ្ឋាន

- បន្តអនុវត្តគម្រោងកិច្ចសហប្រតិបត្តិការជាមួយ GTZ ជាពិសេសក្នុងការរៀបចំមូលដ្ឋានទិន្នន័យស្តីពី មុខងារស្ថាប័នរដ្ឋ

-ត្រៀមរៀបចំសន្និសិទជាតិស្តីពីលទ្ធផលការងារសំខាន់ៗពីឆ្នាំ២០០៥ ដល់ឆ្នាំ២០០៨

-បន្តការរៀបចំសិក្ខាសាលា ស្តីពីកម្មវិធីវេទិកាផ្លាស់ប្តូរយោបល់ជាមួយទីភ្នាក់ងារអនុវត្ត និងសង្គមស៊ីវិល លើបញ្ហាកំណែទម្រង់ច្បាប់ និងប្រព័ន្ធយុត្តិធម៌នៅតាមបណ្តាខេត្តចំនួនបី: កំពង់ចាម កំពង់ធំ និងខេត្តព្រៃវែង នៅក្នុងខែកញ្ញានេះ។

រាជធានី ភ្នំពេញ ថ្ងៃទី៣០ ខែកញ្ញា ឆ្នាំ២០០៩

**អ្នកធ្វើរបាយការណ៍**

**ស៊ុន សិរីវុធ**

បានឃើញ និងឯកភាព

នាយកអង្គភាពគ្រប់គ្រងគម្រោង

**ស៊ុយ ម៉ុងលាង**